# ជីវិត Life

"ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យមាន
ជីវិតយ៉ាងបរិបូរណ៍"។
( យ៉ូហាន:១០,១០)

សកម្មភាពព្រះសហគមន៍ភូមិភាគភ្នំពេញ

លេខ១២ សម្រាប់ថ្ងៃទី០១-២៨ ខែកុម្ភៈ ឆ្នាំ២០១៣





**អេម៉ានូអែល**
សំឡេងព្រះសហគមន៍កាតូលិក **FM 102.5 Mhz**
ម៉ោង ២:០០ - ៣:០០ រាល់ថ្ងៃសុក្រ

**ខ្ញុំត្រូវការអ្នក (I NEED YOU)**
រាល់ថ្ងៃអង្គារ **FM 99.5 Mhz**
ម៉ោង ១០:០០ - ១១:០០ ព្រឹក

# បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គឆ្នាំ ២០១៣

**យើងរួមគ្នា**

**នៅក្នុងឆ្នាំនៃជំនឿ**

យើងត្រូវហ៊ានទៅនៅក្បែរអ្នកតូចតាច ទៅនៅក្បែរអ្នកដែលគេទាត់ចោល និងទៅនៅក្បែរអ្នកដែលគ្មាននរណាស្រឡាញ់យ៉ាងពិតប្រាកដ។

យើងត្រូវតែពង្រីក និងពង្រឹងទំនាក់ទំនងគ្នានិងគ្នាយ៉ាងស្រួលដូចបងប្អូនបង្កើត យើងត្រូវសុខចិត្តរួមសន្ធនាជាមួយអ្នកដទៃ ទាំងយកចិត្តទុកដាក់យល់ចិត្តគំនិតរបស់គេដូចព្រះយេស៊ូយល់ចិត្តគំនិតរបស់យើងម្នាក់ៗដែរ។

យើងត្រូវរួមគ្នាសាងសង់ព្រះសហគមន៍របស់ព្រះយេស៊ូ គឺព្រះសហគមន៍ដែលសុខចិត្តទទួលព្រះវិញ្ញាណដែលត្រាស់ហៅ។ យើងត្រូវបណ្ដោយឲ្យព្រះយេស៊ូប្រទានទឹកឲ្យយើងពិសា ព្រោះមានតែព្រះអង្គទេដែលអាចប្រោសឲ្យយើងលែងស្រេកទឹក គឺអាចផ្ដល់សេចក្ដីសុខសាន្តដ៏ពិតប្រាកដឲ្យយើង។

បងប្អូនជាទីស្រឡាញ់! ក្នុងឆ្នាំ ២០១៣ នេះ យើងនាំគ្នារិះគិតអំពីរបៀបរស់នៅជាព្រះសហគមន៍។ យើងត្រូវសួរដល់ខ្លួនឯងដូចតទៅ៖

- តើយើងត្រូវធ្វើយ៉ាងដូចម្ដេច ដើម្បីឲ្យព្រះសហគមន៍យើងមានលក្ខណៈជាខ្មែរយ៉ាងពិតប្រាកដនៅក្នុងប្រទេសកម្ពុជាយើង?
- តើខ្ញុំត្រូវធ្វើយ៉ាងណា ដើម្បីពង្រឹងទំនាក់ទំនងរបស់ខ្លួននឹងព្រះជាម្ចាស់ បណ្ដោយឲ្យព្រះអង្គប្រែចិត្តគំនិតខ្ញុំឲ្យមានលក្ខណៈដ៏ប្រសើរដូចព្រះអង្គ?
- តើខ្ញុំត្រូវធ្វើដូចម្ដេច ដើម្បីទទួលមនុស្សឯទៀតៗទុកជាព្រះអំណោយទានរបស់ព្រះជាម្ចាស់?

**បពិត្រព្រះបិតាយើងខ្ញុំ**!

យើងខ្ញុំសូមអរព្រះគុណព្រះអង្គចំពោះឆ្នាំនៃជំនឿ។

ព្រះបិតាបានបង្កើតយើងខ្ញុំឲ្យមានលក្ខណៈដ៏ប្រសើរដូចព្រះអង្គ។

ព្រះបុត្រារបស់ព្រះអង្គយាងមកសង្គ្រោះយើងខ្ញុំដោយទ្រង់សោយទិវង្គតនិងមានព្រះជន្មរស់ឡើងវិញ។ ព្រះវិញ្ញាណដ៏វិសុទ្ធគង់សណ្ឋិតក្នុងយើងខ្ញុំ និងណែនាំឲ្យយើងខ្ញុំទៅប្រកាសដំណឹងល្អ។

យើងខ្ញុំសូមអរព្រះគុណព្រះអង្គចំពោះព្រះសហគមន៍ ព្រះសហគមន៍ជាប្រជាជននៃមនុស្សគ្រប់ជាតិសាសន៍ ដែលរួមគ្នាជាផ្លូងតែមួយក្នុងអង្គព្រះយេស៊ូ ជាព្រះបុត្រាព្រះអង្គ។ ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ដដែលថ្វាយនូវអំណរសប្បាយ និងទុក្ខព្រួយរបស់មនុស្សលោកទៅព្រះបិតា។ ព្រះសហគមន៍ជាអ្នកបម្រើដ៏ក្រីក្រដែលរួមដំណើរជាមួយអ្នកតូចតាចដែលត្រូវសង្គមជិះជាន់។

យើងខ្ញុំសូមអរព្រះគុណព្រះអង្គរួមជាមួយព្រះនាងម៉ារីព្រះនាងពិតជា ជាមាតា និងជាគំរូរបស់ព្រះសហគមន៍។ ព្រះនាងប្រគល់ព្រះបុត្រារបស់ព្រះអង្គមកយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំនាំមនុស្សឲ្យបានស្គាល់ព្រះបុត្រា។

យើងខ្ញុំសូមរួមជាមួយសន្ដឺថេរេសានៃព្រះកុមារយេស៊ូ រួមជាមួយអស់មរណសាក្សីមានលោកយ៉ូសែបឆ្នារ សាឡាស និងសហការីរបស់លោកជាដើម រួមដំណើរជាមួយព្រះយេស៊ូដែលជាពន្លឺបំភ្លឺប្រជាជាតិនានា

បពិត្រព្រះបិតាយើងខ្ញុំ!

សូមព្រះអង្គចាត់ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកជួយបំភ្លឺចិត្តគំនិតយើងខ្ញុំផង!។

សូមព្រះជាម្ចាស់ប្រទានពរឲ្យបងប្អូន និងថែរក្សាបងប្អូនក្នុងសេចក្ដីសុខសាន្តរបស់ព្រះអង្គ។

**អូលីវីយេ ស្មិតហាស្សេរ**

ជាអភិបាលរបស់បងប្អូន



# សាលាមត្តេយ្យនៅព្រះសហគមន៍ជុំគីរីត្រូវបានសម្ពោធ





កាលពីរថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ នៅព្រះសហគមន៍ជុំគីរីស្ថិតភូមិតារាជ្យ ឃុំជម្លូវន្ត ស្រុកជុំគីរី ខេត្តកំពតបានប្រារព្ធពិធីសម្ពោធសាលាមត្តេយ្យថ្មីមួយខ្នងធ្វើអំពីថ្ម ដោយមានការចូលរួមពីសំណាក់លោកអភិបាលអូលីវីយេ បេងប្រុសបងស្រីនិងបងប្អូនគ្រីស្តបរិស័ទអាជ្ញាធរភូមិឃុំ សរុបប្រមាណជាង៣០០នាក់។ នៅក្នុងឱកាសនោះ លោកអភិបាលអូលីវីយេបានមានប្រសាសន៍ថា ព្រះសហគមន៍យើងនៅក្នុងប្រទេសកម្ពុជាបានយកចិត្តទុកដាក់ចំពោះបងប្អូនទាំងអស់មិនថាគ្រីស្តបរិស័ទឬ មិនមែនជាគ្រីស្តបរិស័ទ ហើយសាលាមត្តេយ្យថ្មីដែលទើបតែសម្ពោធនេះ ស្វាគមន៍កុមារទាំងអស់នៅក្នុងភូមិឲ្យទទួលបានការអប់រំទាំងអស់គ្នា។

លោកបូជាចារ្យលូកា ដែលមាននាទីទទួលខុសត្រូវមណ្ឌលសកម្មភាពកំពតបានគូសបញ្ជាក់ថា សាលាមត្តេយ្យនេះ យើងមានពីយូរមកហើយតែធ្វើអំពីឈើ។ តែមកដល់ពាក់កណ្តាលឆ្នាំ២០១១ លោកបានស្នើរសុំទៅលោកអភិបាលដើម្បីកសាងសាលាមត្តេយ្យថ្មីសង់អំពីថ្មមួយខ្នងទៀតដែលចំណាយអស់ទឹកប្រាក់សរុបជាច្រើនម៉ឺនដុល្លារ ហើយកសាងរួចរាល់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២នេះ។ លោកបានបន្តទៀតថា សម្រាប់សាលាមត្តេយ្យចាស់ដែលធ្វើអំពីឈើនោះ ក៏បានកែលំអរជាថ្មីដោយលើកឲ្យខ្ពស់ពីដីផ្នែកខាងលើខណ្ឌជាបន្ទប់ៗសម្រាប់ទទួលភ្ញៀវ និងផ្នែកខាងក្រោមក៏ចែកបន្ទប់សំរាប់ដាក់កុំព្យូទ័រ ឃ្លាំងនិងបន្ទប់សម្រាប់ឲ្យសិស្សានុសិស្សរៀនគួរមុខវិជ្ជាផ្សេងៗផងដែរ។

## New Kindergarten Inaugurated at Chumkiri

A kindergarten building with two classrooms and one big meeting room was officially inaugurated at Chumkiri community, Kompot province recently. The building measures 120 meters wide.

Bishop Olivier of the Vicariate of Phnom Penh said that the Catholic Church in Cambodia has been working very hard to provide educational opportunities to the young generation of today. “We give all the children the same chances and possibilities no matter where and which family background they come from; we simply care that much about their future and we only want them to have the opportunity to receive good education,” the Bishop added.

According to Fr. Gianluca Tavola, priest in charge of the Kompot Pastoral Center, the school was built from the support of a group of Singapore youth, of some Catholics in Italy and one NGO in Cambodia. About 100-150 kids come for the scout program and are given nutritious food every Sunday.

# ព្រះសហគមន៍អរិយក្សត្ររកឃើញរូបសំណាកព្រះនាងម៉ារីទីពីរ នៅបាតទន្លេមេគង្គ





រូបសំណាកព្រះនាងម៉ារី កំពស់ជាង២ម៉ែត្រ ត្រូវបានរកឃើញនៅបាតទន្លេមេគង្គ កាលពីថ្ងៃទី១៩ វិច្ឆិកាកន្លងទៅ ដោយបុរសម្នាក់ ឈ្មោះ ផាង វ៉ាំងហ៊ូ ជាពុទ្ធបរិស័ទដែលរស់នៅភូមិអរិយក្សត្រ។ លោក ផាង វ៉ាំងហ៊ូ បានរៀបរាប់ហេតុការណ៍យ៉ាងនេះថា៖ នៅយប់ថ្ងៃទី១៨ វិច្ឆកា លោកបានយល់សុបិន្តឃើញរូបសំណាកមួយធ្វើពីស្ពាន់ មានរូបរាងដូចមនុស្សប្រុសមាឌធំ រូបនោះបាននិយាយមកគាត់ថា "សូមស្រង់ខ្ញុំឡើង ខ្ញុំកំពុងស្ថិតនៅបាតទន្លេមេគង្គ ខ្ញុំនៅជិតកន្លែងដែលបានស្រង់រូបសំណាកព្រះនាងម៉ារីពីមុន"។ លោកហ៊ូអះអាងថា ទោះបីលោកជាពុទ្ធ បរិស័ទ ប៉ុន្តែលោកតែងតែមកអធិដ្ឋាននៅមុខរូបសំណាក់ព្រះនាងម៉ារី ដែលបានរកឃើញក្នុងបាត ទន្លេកាលពីពេលកន្លងទៅ។ ការបួងសួងរបស់លោកក៏បានទទួលផលខ្លះៗដែរ។ ដោយចិត្តរំភើបលោកហ៊ូ បន្តថានេះជាការអស្ចារ្យសម្រាប់រូបលោក។ លោកសូមប្រគល់រូបសំណាក ព្រះនាងម៉ារីនេះ ទៅព្រះវិហារ អរិយ្យក្សត្រ ហើយលោកបន្តអធិដ្ឋានទៅព្រះនាងម៉ារីសូមជួយថែរក្សាប្រពន្ធរបស់លោកដែលកំពុងមានជំងឺឲ្យបានជាសះស្បើយផង។

សូមបញ្ជាក់ថា រូបសំណាក់ព្រះនាងម៉ារីទី១ បានរកឃើញដោយជនជាតិឥស្លាមនៅឆ្នាំ២០០៨ និងលើកទី២នេះ ត្រូវបានរកឃើញដោយអ្នកមុជទឹក ជាពុទ្ធបរិស័ទ។

## Second Marian Statue Found in Mekong River

A second statue of Mary was found in the Mekong River by a Buddhist family living at Arrey Ksat, along the Mekong River.

Mr. Phang Vang Hou, the discoverer of the statue, narrated that what happened was truly a miracle. On November 19, 2012 he dreamt that a person was calling him for help. The person wanted to be lifted up out of the water as he was very cold. In the morning, Mr. Phang told everybody in the village about his dream but nobody seemed to believe him or take interest in the dream. In that morning at about 7 am, he and his two sons went to look for it in the water. After several minutes, they found the statue which was so heavy that the three of them couldn't lift it up. So they rushed to rent a machine and they succeeded.

This the second Mary statue which has been found in the Mekong River.

# លោកអភិបាលបង្រៀនអំពីឆ្នាំនៃជំនឿនៅព្រះសហគមន៍ចំប៉ា

នៅក្នុងរដូវរង់ចាំនេះ លោកអភិបាលបានធ្វើដំណើរតាមព្រះសហគមន៍នានាដើម្បីធ្វើការបង្រៀន និងសួរសុខទុក្ខព្រះសហគមន៍តាមមណ្ឌលសកម្មភាពក្នុងភូមិភាគភ្នំពេញ។ កាលពីថ្ងៃទី៨ ធ្នូកន្លងទៅនេះ លោកអភិបាលបានទៅបង្រៀន និងសំណេះ សំណាលជាមួយគ្រីស្តបរិស័ទនៅព្រះសហគមន៍ចំប៉ា។

ក្នុងឱកាសនោះ លោកអភិបាលបានយកចិត្តទុកដាក់ណែនាំគ្រីស្តបរិស័ទឲ្យយល់ច្បាស់អំពីអត្ថន័យនៃឆ្នាំនៃជំនឿ។ លោកបានផ្តោតសំខាន់ទៅលើជីវិតជាគ្រីស្តបរិស័ទ។ ក្នុងនោះលោកសង្កត់ធ្ងន់ទៅលើចំនុច ពីរសំខាន់ៗគឺ យើងរួមគ្នាក្នុងព្រះសហ-គមន៍ និងព្រះសហគមន៍នៅប្រទេសកម្ពុជាកំពុងមានការរីកចម្រើន។ លោកបន្តថា គ្រូអប់រំជំនឿមានតួនាទីសំខាន់ក្នុងព្រះសហគមន៍ដើម្បីបន្តបេសកកម្មក្នុងការប្រកាសដំណឹងល្អឲ្យអ្នកដទៃស្គាល់អំពីព្រះយេស៊ូ និងឲ្យគេចូលរួមកាន់តែច្រើនក្នុងព្រះសហគមន៍។ លោកអភិបាលបានបង្ហាញវិធីមួយចំនួនដើម្បីឲ្យយើងម្នាក់អាចធ្វើបានក្នុងកិច្ចដ៏លំបាកនេះ គឺយើងត្រូវបង្ហាញសេចក្តីស្រលាញ់ យកចិត្តទុកដាក់ជាមួយអ្នកក្រីក្រ បន្ទាបខ្លួនដូចព្រះយេស៊ូ និងចេះចែករំលែកគ្នាទៅវិញទៅមក។

លោកអ៊ំ ហ្វាង ជាគ្រីស្តបរិស័ទម្នាក់មានប្រសាសន៍ថា ការចំណាយពេលវេលាដ៏សំខាន់របស់លោកអភិបាលពិតជាមានសារៈសំខាន់ណាស់ព្រោះ គ្រីស្តបរិស័ទមានឱកាសយល់ដឹងនិងស្វែងយល់អំពីជំនឿនិងព្រះសហគមន៍បានស៊ីជម្រៅ។

នៅចុងបញ្ចប់លោកអភិបាលបានសួរសំនួរដ៏សំខាន់ពីរគឺ តើហេតុអ្វីបានជាយើងស្រលាញ់ព្រះសហគមន៍? និងតើយើងម្នាក់ៗមានសំណូមពរឲ្យព្រះសហគមន៍ធ្វើអ្វីថែមទៀត?

## Bishop Explains ‘’Year of Faith” to Parishioners in Champa

During the Advent season, Bishop Olivier took his significant journey to each pastoral center to give a talk about the Year of Faith. The Catholics in Champa parish welcomed him for a short recollection last December 8, 2012.

On this special occasion, the Bishop stressed the importance of the Year of Faith. He pointed out that the Cambodian Church is slowly growing in depth. He added that catechists play a very vital role in proclaiming and bringing more people to God. To do this difficult task, the Bishop recommended us to share our lives with the poor, be



# ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន ធ្វើទស្សនកិច្ចនៅមណ្ឌល រ

ឯកឧត្តមបណ្ឌិត ច័ន្ទ សារុនរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រួមនិងគណៈ ប្រតិភូអមដំណើរ កាលពីរសៀល ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣កន្លងទៅនេះ បានធ្វើដំណើរ មក ទស្សនៈកិច្ច នៅមណ្ឌលភូមិសុខសាន្ត ស្ថិតក្នុងភូមិពងទឹក ខាងត្បូង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។

ក្នុងដំណើរទស្សនៈកិច្ចរបស់ឯកឧត្តមបណ្ឌិតនាឱកាសនោះ ក៏មានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់លោកសុខកុមារ អូលីវីយេ ផ្ទឹតអីស្លែរ អភិបាលភូមិភាគភ្នំពេញ នាយិកាអង្គការ ឱកហ្វី លោកធន ឈិន ប្រធានក្រុមប្រឹក្សាស្រុកត្រាំកក់ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស ព្រមទាំង មាតាបិតាសិស្សនិងក្រុមគ្រួសារអ្នកជម្ងឺយ៉ាងច្រើនកុះករ ។

ថ្លែងរាយការណ៍សង្ខេបអំពីសកម្មភាពការងារក្នុងមណ្ឌល ភូមិសុខសាន្តអ្នកស្រីមួងសុភាពនាយិកា អង្គការ ឱកហ្វី បានជំរាប ជូនភ្ញៀវនូវសកម្មភាព និងគំរោងការណ៍នានារបស់អង្គការដែល និងគ្រោងធ្វើក្នុងឆ្នាំ២០១៣នេះ។ អ្នកស្រីបានឲ្យដឹងថា៖ នៅ ក្នុងមណ្ឌលភូមិសុខសាន្តមាន កម្មវិធីចំនួន៥គឺ៖ កម្មវិធីគាំទ្រ ដល់គ្រួសារអ្នកជម្ងឺអេដស៍ កម្មវិធីមណ្ឌលថែទាំសុខភាពកុមារពិ ការប្រចាំសប្តាហ៍ កម្មវិធីអប់រំ កម្មវិធីកសិកម្ម និងកម្មវិធីសិប្ប កម្ម។ អ្នកស្រីបញ្ជាក់ថា៖ ការបង្កើតមណ្ឌលភូមិសុខសាន្តនេះ ក្នុងគោលបំណង លើកទឹកចិត្តអ្នកជម្ងឺ ក្រុមគ្រួសារ និងកុមារ ពិការ ដើម្បីជួយពួកគេឲ្យមានសេចក្តីសង្ឃឹមនិងរស់នៅដោយមាន សេចក្តីសុខយ៉ាងពិតប្រាកដក្នុងជីវិត។

លោកធន ឈិន ប្រធានក្រុមប្រឹក្សាស្រុកត្រាំកក់ បានធ្វើ របាយការណ៍សង្ខេបទូទៅអំពី សភាពការណ៍និងការអភិវឌ្ឍន៍ក្នុង ស្រុកត្រាំកក់ទាំងមូល ជូនគណៈអធិបតីនាឱកាសនោះ ដោយ បញ្ជាក់ថា៖ ការបង្កបង្កើតផលនារដូវវស្សាឆ្នាំ២០១២នេះ ផ្ទៃដី បង្កបង្កើតផលទូទាំងស្រុកមានចំនួន ៣៤៧០០ហិកតា។ តាម គម្រោងផែនការបង្កបង្កើត ផលស្រូវបង្កើនរដូវមានចំនួន១៧០០ ហិកតា សម្រេចបាន ១៧៩៩ហិកតា ស្រូវរដូវវស្សាសម្រេចបាន ចំនួន៣៤៧០០ហិកតា ស្មើនិង១០៥.១៧ភាគរយ។ ការច្រូត កាត់បានចប់សព្វគ្រប់លើផ្ទៃដីចំនួន៣៦៤៩៩ហិកតា។ គិតជា មធ្យម១ហិកតា ទិន្នផលទទួលបានចំនួន៣៤៤០គក្រ ។

មានប្រសាសន៍ក្នុងឱកាសនោះ លោកអភិបាលបានឲ្យដឹង ថា៖ នៅថ្ងៃនេះយើងទាំងអស់ មានអំណរនិងកិត្តិយសដែល ឯកឧត្តមបានមកសួរសុខទុក្ខយើង ។ ភូមិសុខសាន្តនេះបង្កើតបាន មួយឆ្នាំកន្លះហើយ ប៉ុន្តែគឺជាការ









# ភូមិសុខសាន្ត

ប្រមូលនូវសកម្មភាពការងារ អំពីបងប្អូនដែលមានផ្ទុកមេរោគអេដស៍នៅភ្នំវល្លិ៍ ចាប់តាំងពីឆ្នាំ២០០៣មក។ គោលដៅរបស់យើងគឺណែនាំឲ្យបងប្អូនទាំងអស់ រស់នៅទីនេះឲ្យរកឃើញសេចក្តីសុខនៅក្នុងជីវិតនិងមើលឃើញអំពីជីវិតរបស់យើងម្នាក់ៗមានតម្លៃថ្លៃថ្នូរ គឺយើងម្នាក់ៗមានតម្លៃណាស់។ ខ្ញុំសង្ឃឹមថាភូមិសុខសាន្តនេះ ជាភូមិមួយដ៏ពិសេសដែល កសាងសេចក្តីសុខសាន្ត ប្រសិនបើយើងសុខចិត្តសហការគ្នា។ មនុស្សទាំងអស់ទោះបី មានជម្ងឺ ក្រីក្រ មានឋានៈខ្ពស់ មិនមានចំណេះដឹងក៏ដោយ យើងជាអ្នកពិការក៏ដោយ យើងទាំងអស់គ្នា ទទួលសេចក្តីសុខសាន្តបាននៅក្នុងជីវិតរបស់យើង។ នៅចុងបញ្ចប់លោកអភិបាលបានថ្លែងអំណរគុណចំពោះ បុគ្គលិកអង្គការឪកហ្វីនិងអ្នកស្ម័គ្រចិត្តទាំងអស់ ដែលបានជួយយកចិត្តទុកដាក់ដល់កូនក្មេងពិការ និងគ្រួសារអ្នកជម្ងឺនៅទីនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម ដែល បានយកចិត្តទុកដាក់ និងមកសួរសុខទុក្ខយើង ព្រមទាំងផ្តល់កម្លាំងកាយចិត្តឲ្យយើងទាំងអស់គ្នា ។

ឯកឧត្តមបណ្ឌិតច័ន្ទ សារុនមានប្រសាសន៍ថា ៖ ក្នុងនាមជាប្រធានក្រុមការងារចុះជួយស្រុកត្រាំកក់ និងតំណាងឲ្យអាជ្ញាធរមូលដ្ឋានក្នុងស្រុកត្រាំកក់ទាំងមូលខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោកអភិបាលអូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលបានផ្តួចផ្តើមគំនិតកសាងភូមិសុខសាន្តនេះឡើង និងបានខិតខំយកចិត្តទុកដាក់ដល់អ្នកជម្ងឺ និងក្មេងៗពិការទាំងនេះ។ យើងចង់ឲ្យភូមិនេះក្លាយទៅភូមិសុខសាន្ត ដូចដែលលោកអភិបាលបានបញ្ជាក់អត្ថន័យពីខាងដើម ។ ការដាក់ឈ្មោះភូមិសុខសាន្តនេះគឺក្នុងស្មារតីមួយ កសាងសង្គមមួយឲ្យមានសេចក្តីសុខសាន្ត។

ចុងបញ្ចប់កម្មវិធីឯកឧត្តមបណ្ឌិតច័ន្ទ សារុន បានទស្សនាសកម្មភាពក្នុងមណ្ឌល សួរសុខទុក្ខកុមារពិការនិងក្រុមគ្រួសារអ្នកជម្ងឺតាមផ្ទះនីមួយៗ ព្រមទាំងចែកអំណោយនូវគ្រឿងឧបភោគបរិភោគដល់គ្រួសារអ្នកជម្ងឺ កុមារពិការ សិស្សានុសិស្ស ដែលបានចូលរួមផងដែរ។ អំណោយ សម្រាប់គ្រួសារអ្នកជម្ងឺ ក្នុង១គ្រួសារទទួលបាន ៖ កន្ទុនជ័រ១ ភួយ១ សារុង២ ក្រមា២ មី១កេះម្សៅសាប៊ូ១គក្រ ទឹកក្រូច២ដប សាប៊ូក្រអូប៦ដុំ ស្ករ១គក្រ ទឹកដោះគោឆៅ១ឡូ ត្រីខ១ឡូ ទឹកស៊ីអ៊ីវ១យួរ ទឹកត្រី១យួរ ថវិការ ២០០០០រៀល។ ក្នុងនោះដែរឯកឧត្តមបណ្ឌិតបានសន្យា ផ្តល់កូនជ្រូកពូជចំនួន២៤ក្បាល និងស្រូវពូជសម្រាប់មណ្ឌលភូមិសុខសាន្តនេះផងដែរ។







# ក្រុមតេរេសាមណ្ឌលបាសាក់ចូលរួមសំណាក់ធម៌នៅព្រះសហគមន៍ជ្រៃធំ



ក្រុមតេរេសាទាំង២០៤នាក់ដែលមកពីព្រះសហគមន៍ទាំង៦ នៅក្នុងមណ្ឌលសកម្មភាពទន្លេបា សាក់បានជួបជុំគ្នាសំណាក់ធម៌ និងធ្វើសច្ចានៅព្រះសហគមន៍កាតូលិកជ្រៃធំក្រោមការដឹកនាំរបស់លោកអភិបាលអូលីវីយេ កាលពីរសៀលថ្ងៃទី២៤ ខែវិច្ឆកា ឆ្នាំ២០១២។

ក្នុងពេលនោះដែលោកអភិបាលបានណែនាំអំពីប្រវត្តិរបស់សន្តីតេរេសាកាលកុមារភាពរហូតដល់សន្តីទទួលមរភាព។ លោកក៏បានលើកឡើងនូវចំណុចសំខាន់របស់សន្តីតេរេសាដើម្បីជាគំរូសម្រាប់ក្រុមតេរេសាទាំងអស់ធ្វើតម្រាប់តាម។ ចំណុចសំខាន់ដែលលោកអភិបាលបានលើកឡើងនោះគឺ កាអធិដ្ឋានរាល់ថ្ងៃក្នុងមួយសប្ដាហ៍តាមរបៀបសន្តីតេរេសាបានអធិដ្ឋានជាមួយព្រះអម្ចាស់។ ថ្ងៃច័ន្ទអធិដ្ឋានសម្រាប់លោកតា លោកយាយ។ ថ្ងៃអង្គារអធិដ្ឋានសម្រាប់ក្រុមគ្រួសារ។ ថ្ងៃពុធអធិដ្ឋាន ជាមួយសន្តៈយ៉ូសែបសម្រាប់អស់ក្រុមគ្រួសារកាតូលិក។ ថ្ងៃព្រហស្បតិ៍អធិដ្ឋានសម្រាប់សម្ដេចប៉ាប លោកអភិបាល និងអស់លោកបូជាចារ្យបងប្រុសបងស្រី។ ថ្ងៃសុក្រអធិដ្ឋានសម្រាប់អស់អ្នកដែលមិនទាន់ស្គាល់ព្រះជាម្ចាស់និងអស់អ្នកដែលវង្វេងជំនឿរបស់ខ្លួនលើព្រះជាម្ចាស់។ ថ្ងៃសៅរ៍អធិដ្ឋានសម្រាប់ក្រុមតេរេសាទាំងអស់ក្នុងនាមយើងជាកុមារតេរេសាមាគ៌ាតូចស្វែងរកព្រះជាម្ចាស់ហើយយេជាផ្លូវតូចរបស់ព្រះយេស៊ូផងដែរ។

ក្រោយពេលសំណាក់ធម៌ចប់ លោកអភិបាលបានដាក់ធាតុរបស់សន្ត Theophane និងថ្វាយអភិបូជាទទួលពាក្យសច្ចារបស់ក្រុមមាគ៌ាតូចតេរេសា។

## 204 Children from Teresa Group Attend Recollection and Make Vows

About 204 kids from the “Teresa Group” gathered together for their retreat and make their vows at Chrey Thom Pastoral Center November 24, 2012. On that day, Bishop Olivier introduced St. Teresa of the Child Jesus to the children, beginning from her early life until her death. He pointed out some virtues and examples which would be useful to help guide those kids. The Teresa group will have regular prayers for the week: Monday is for older people, Tuesday is for families, Wednesday is for praying with St. Joseph for Catholic families, Thursday is for the Pope, Bishops and those who devote their lives for the Church, Friday for the people who haven’t yet found Jesus in their lives and for those who are away from God, Saturday is for their group, “Teresa” to be the way which can lead them to Jesus.

# គ្រីស្តបរិស័ទ ៦២នាក់ ទទួលពិធីលាបថ្ងាសនៅមណ្ឌលសកម្មភាពទន្លេបាសាក់

មានគ្រីស្តបរិស័ទចំនួន៦២នាក់នៅព្រះសហគមន៍ដៃធ្រំបានទទួលពិធីលាបថ្ងាស់ក្រោមអធិបតីភាពរបស់លោកអភិបាល អូលីវីយេកាលពីថ្ងៃទី២៤ វិច្ឆកា ២០១២កន្លងទៅនៅព្រះសហគមន៍កាតូលិកជ្រៃធំ។

លោកអភិបាលមានប្រសាសន៍ ណែនាំគ្រីស្តបរិស័ទទាំងអស់ដោយលើកឡើងអំពីឆ្នាំនៃជំនឿ គឺយើងរួមរស់ជាព្រះសហគមន៍ និងជឿថាព្រះគ្រីស្តជាពន្លឺបំភ្លឺមនុស្សលោកា ហើយយើងទាំងអស់គ្នាជាព្រះសហគមន៍ដោយមានតួនាទីសំខាន់គឺ ការប្រកាស់ដំណឹងល្អអំពីព្រះរាជ្យព្រះជាម្ចាស់ ការអធិដ្ឋានគ្រប់ពេលវេលា និងការបង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដល់អ្នកដទៃ។ លោកអភិបាលក៏បានមានប្រសាសន៍ក្នុងធម្មទេសនាទៀតថា ក្នុងនាមយើងជាគ្រីស្តបរិស័ទម្នាក់ៗត្រូវមានតួនាទីបំរើព្រះជាម្ចាស់ដោយសេចក្តីស្រលាញ់និងធ្វើជាសាក្សីរបស់ព្រះអង្គហើយ ព្រះវិញ្ញាណនិងផ្តល់ឲ្យយើងមានភាពក្លាហាន ភាពឈ្លាសវៃ ដឹងខុសត្រូវ និងភាពសច្ចធម៌ ហើយទ្រង់និងជួយយើងរស់នៅកាន់តែជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់។

លោក សិលា ជាអ្នកទទួលខុសត្រូវនៅមណ្ឌលសកម្មភាពទន្លេបាសាក់មានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសម្រាប់ការយកចិត្តទុកដាក់របស់លោក អភិបាលចំពោះព្រះសហគមន៍និងគ្រីស្តបរិស័ទទាំងអស់ជាពិសេសរាល់កម្មវិធីអគ្គសញ្ញាក្នុងព្រះសហគមន៍។ លោកក៏បានបន្តទៀតថា រូបលោកនិងគ្រីស្តបរិស័ទទាំងអស់មានអំណរសប្បាយយ៉ាងខ្លាំងនៅពេលលោកអភិបាលមកថ្វាយអភិបូជាម្តងៗ

## 62 Catholics Receive Confirmation at Tonle Basac Pastoral Center

A total of 62 persons in Tonle Basac Pastoral Center received the sacrament of Confirmation last November 24, 2012 at Chrey Thom Parish.

Bishop Olivier advised them and the whole assembly that in this Year of Faith, and since they were Catholics, they must always be united and reconciled in order to bring the light of God to the world. "The Church has a great mission to proclaim the Good News to others," said the Bishop. He also reminded them of our responsibility to serve others and be God's witnesses.

"The Holy Spirit, I believe, will fill us with courage, grant us gifts and talents in order to promote justice and peace in our world," said Bishop Olivier.



# សកម្មភាពព្រះសហគមន៍នៅ













# នៅក្នុងបុណ្យព្រះយេស៊ូប្រសូត















# ព្រះសហគមន៍ប្រារព្ធពិធីបើកឆ្នាំនៃជំនឿរួមគ្នានិងរំលឹក ខួបទី ៥០

ព្រះសហគមន៍នៅប្រទេសកម្ពុជាបានរួមគ្នាប្រារព្ធពិធីបើកឆ្នាំនៃជំនឿ និងខួបទី៥០ នៃមហាសន្និបាតវ៉ាទីកង់ទី២ ដែលភូមិភាគភ្នំពេញជាម្ចាស់ផ្ទះក្នុងការរៀបចំ និងទទួលស្វាគមន៍ភូមិភាគពីរផ្សេងទៀត កាលពីថ្ងៃទី៥-៧ ខែមករា កន្លងទៅនេះ។

ក្នុងឱកាសនោះ លោកអភិបាលអូលីវីយេ បានណែនាំ និងធ្វើការពន្យល់ពីមូលហេតុនៃការជួបជុំដែលមិនធ្លាប់មានតាំងពីមុនមកក្នុងប្រវត្តិសាស្ត្រ ដើម្បីរំលឹកនិងស្វែងយល់ពីសារៈសំខាន់នៃមហាសន្និបាតវ៉ាទីកង់ទី២។ លោកអភិបាលបានមានប្រសាសន៍ថា តាមរយៈកិច្ចខំប្រឹងប្រែងរបស់សម្តេចប៉ាបយ៉ូហានទី២៣ក្នុងការប្រមប្រមូលលោកអភិបាលទូទាំងពិភពលោកបាននាំគ្នា រិះគិតពិចារណាអំពីរបៀបដែលព្រះសហគមន៍ត្រូវប្រកាសដំណឹងល្អ គិតអំពីរបៀបដែលព្រះសហគមន៍ត្រូវធ្វើបុណ្យ គិតអំពីរបៀបទំនាក់ទំនងរវាងព្រះសហគមន៍ និងសង្គម និងសាសនាដទៃទៀត។ លោកអភិបាលបានបន្តទៀតថា លទ្ធផលដែលចេញពីមហាសន្និ














# ទី ៥០នៃមហាសន្និបាតវ៉ាទីកង់ទី២

បាត់វ៉ាទីកង់ទី២នោះ បានជួយឲ្យព្រះសហគមន៍ធ្វើដំណើរទៅមុខតាមរបៀបមួយត្រឹមត្រូវ និងរក្សាព្រះសហគមន៍ទូទាំងពិភពលោកឲ្យស្ថិតក្នុងមហាគ្រួសារតែមួយ។

កម្មវិធីសមាជទាំងមូលប្រព្រឹត្តទៅដោយមានការចាប់ផ្តើមអធិដ្ឋាន និងសេចក្តីបង្រៀនរបស់លោកអភិបាលអូលីវីយេអំពីឆ្នាំនៃជំនឿរួមរស់ជាព្រះសហគមន៍ ហើយតំណាងព្រះសហគន៍ទាំងអស់មានឱកាសដើម្បីទទួលការអប់រំតាមកន្លែងផ្សេងៗគ្នាទៅតាមប្រធានបទដែលត្រូវយកមករិះគិតតាមថ្ងៃ។ មុននឹងសមាជត្រូវបញ្ចប់ លោកអភិបាលបានប្រគល់សៀវភៅ ដែលចងក្រងស្តីអំពីមហាសន្និបាតវ៉ាទីកង់ទី២ ដល់តំណាង ព្រះសហគមន៍នីមួយៗក្នុងភូមិភាគទាំងបី និងតំនាងក្រុមបព្វជិតបព្វជិតាសាសនទូត ព្រមទាំងអង្គការកាតូលិកទាំងអស់ដែលកំពុងបំពេញកិច្ចការបម្រើព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា។












# តំណាងព្រះសហគមន៍បឹងទំពុន និងផ្សារតូចចូលគោរពព្រះបរមសពសម្តេចតា





តំណាងព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពុន ២៣នាក់ ដឹកនាំដោយលោកបូជាចារ្យ ហ្គូស្តាវ៉ូ តំនាងមកពីព្រះស ហគមន៍ផ្សារតូច ដឹកនាំដោយលោកអភិបាលអូលីយេបានចូលទៅគោរពព្រះបរមសពព្រះករុណា ព្រះបាទសម្តេចនរោត្តម សីហនុព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ កាលពីថ្ងៃទី៣០ខែធ្នូឆ្នាំ ២០១២កន្លងទៅនេះ។

លោក ថុង ថន ជាតំណាងម្នាក់បានប្រាប់ឲ្យដឹងថា គណៈកម្មការព្រះសហគមន៍កាតូលិកបឹងទំពុន មានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការចូលរួមរំលែកព្រះរាជមរណទុក្ខរបស់អតីតព្រះមហាក្សត្រជាតិខ្មែរ ដូច្នេះហើយទើបតំណាងព្រះសហគមន៍បានសរសេរលិខិតស្នើសុំការអនុញ្ញាតិពីព្រះបរមរាជវាំង។ លោកបានបន្តថា ក្នុងឱកាលនោះព្រះសហគមន៍បានប្រគល់លិខិតចូលរួមរំលែកព្រះរាជមរណទុក្ខ និងបានអធិដ្ឋានសូត្រធម៌បពិត្រព្រះនាងម៉ារី និងធម៌ឱព្រះបិតា។ លោកបន្ថែមថា ដោយពេលវេលាមានកំណត់ តំណាងព្រះសហគមន៍ចុះហត្ថលេខានៅពេលបញ្ចប់។

## Boueng Tumpun Parishioners Pay Respect to Late King Norodom Sihanouk

About 23 representatives from Boueng Tumpun Church and dozen from St. Joseph parish went to the Royal Palace to pay respect to the late King Norodom Sihanouk last December 30, 2012.

Mr. Thong Than, a member of the delegation, said: “As Cambodian Catholics, we were given this special time to express our grief for the loss of a great King. This also showed our solidarity, as a minority church, with the whole nation; we are not apart and we are not alone.” He added that all the participants had a very short time to pray for the King whom they believe is now resting in peace with God.

# ព្រះអង្គម្ចាស់នរោត្តម រ៉ាវីចក្រ យាងសួរសុខទុក្ខក្រុមគ្រួសារអ្នកជំងឺ និងកុមារពិការនៅមណ្ឌលភូមិសុខសាន្ត



ព្រះអង្គម្ចាស់នរោត្តម រ៉ាវី ចក្រ ជាព្រះរាជបុត្ររបស់សម្តេចព្រះនរោត្តមចក្រពង្សយាងសួរសុខទុក្ខអ្នកជំងឺនៅមណ្ឌលភូមិសុខសាន្តស្ថិតនៅភូមិពងទឹកខាងត្បូង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ កន្លងទៅនេះ។

អ្នកស្រីមួង សុភាព នាយិកាអង្គការឱកហ្វី (មូលនិធិយុវជនកុមារពិការដើម្បីការអប់រំ និងមុខរបរ) បានឲ្យដឹងថា អង្គការឱកហ្វី និងមណ្ឌលភូមិសុខសាន្តចាប់ផ្តើមដំណើរការ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ កន្លងមកនេះ។ មណ្ឌលភូមិសុខសាន្តបង្កើតឡើងដោយលោកអភិបាលសុខកុមារ អូលីវីយេ ក្នុងគោលបំណងលើកទឹកចិត្តអ្នកជំងឺអេដស៍ ក្រុមគ្រួសារ និងកុមារពិការដើម្បីជួយឲ្យពួកគេមានសេចក្តីសង្ឃឹម និងរស់នៅដោយមានសេចក្តីសុខយ៉ាងពិតប្រាកដនៅក្នុងជីវិត។

លោកអភិបាល អូលីវីយេ មានប្រសាសន៍ថា៖ ការជួបជុំគ្នានៅថ្ងៃនេះ គឺជាការលើទឹកចិត្តគ្នាម្យ៉ាង និងជាការសួរសុខទុក្ខគ្នាទៅវិញទៅមក។ យើងចង់ឲ្យភូមិសុខសាន្តនេះប្រែក្លាយទៅជាភូមិមួយ ដែលមានជីវិត ដែលធ្វើឲ្យអ្នកទាំងអស់រស់នៅទីនេះមានសកម្មភាពរស់រវើក ព្រមជាមួយនឹងក្តីសង្ឃឹមថ្មីនៅក្នុងជីវិត។ លោកអភិបាលសូមថ្លែងអំណរគុណចំពោះព្រះអង្គម្ចាស់នរោត្តម រ៉ាវីចក្រ និងអ្នកអង្គម្ចាស់នរោត្តម អេមីន នាយិកាអង្គការអេកស៊ិន អេដ អេហ្សៀ ប្រចាំនៅប្រទេសកម្ពុជា ដែលតែងតែគាំទ្រពេញទំហឹងដល់គម្រោងនានានៅក្នុងមណ្ឌលភូមិសុខសាន្តនេះ។

មានព្រះរាជបន្ទូលនាឱកាសនោះ ព្រះអង្គម្ចាស់នរោត្តម រ៉ាវីចក្រ ថ្លែងអំណរគុណចំពោះលោកអភិបាលអូលីវីយេ និងអង្គការឱកហ្វី ព្រមជាមួយអង្គការ អេកស៊ិន អេដ អេហ្សៀ ជាដៃគូរដែលបានជួយឲ្យមណ្ឌលនេះមានការរីកចម្រើន។

# Prince Norodom Ravichak Visits Peace Center

Prince Norodom Ravichak, a son of Prince Norodom Chakrapong, paid a remarkable visit to the Peace Center in Takeo Province last December 6, 2012.

This significant visit of the Prince was responded by a warm welcome by Bishop Olivier and the many Cambodian families present.

Bishop Olivier said that this was a very special opportunity which could bring us together as a community and share God's love and blessings. "The Peace Center has moved and transformed many lives, especially of the people who stay there. It has brought hope to them," said the Bishop .

The Peace Center is a place which was purposely created for the HIV/AIDS patients. Under the care of the Catholic Church, it provides an opportunity for the patients to develop themselves and find dignity in life, so that they can live in hope. At present, there are nine families there with more than 40 members.

# សម្រង់សេចក្ដីអធិប្បាយព្រះបន្ទូល របស់លោកអភិបាលអូលីវីយេ ឝ្មីតអឺស្លែរ ថ្ងៃទី០៧/០១/២០១៣

១. សូមថ្លែងព្រះគម្ពីរដំណឹងល្អអំពីលោកសាខេ

លោកអភិបាល លោកឪពុកបងប្រុសបងស្រី បងប្អូនគ្រីស្ដបរិស័ទទាំងអស់ បងប្អូនដឹងហើយថាក្នុងចំណោមយើងមានផលយ៉ាងច្រើនដែលដាំ នឹងអនាគតមានអាប៉ូឡូសដែលស្រោចទឹក។ អនាគតទៀត មានបាណាបាស់ដែលច្រូត ក៏ប៉ុន្តែសំខាន់បំផុតគឺមានតែព្រះជាម្ចាស់ដែលណែនាំអោយយើងដុះ។ យើងដឹងហើយ ប្រសិនបើថ្ងៃស្អែកយើងដាំដើមត្នោតមួយទោះបីខ្ញុំស្រោចទឹកជារៀងរាល់ថ្ងៃ ក៏ខ្ញុំឥតមានសមត្ថភាពអោយវាដុះលឿន មានតែព្រះជាម្ចាស់ដែលជំរុញ។ ហេតុនេះហើយថ្ងៃនេះជាពេលវេលាមួយ ដែលយើងត្រូវតែចាប់ផ្ដើមដាំខ្លះៗ លើវាលស្រែនៃព្រះសហគមន៍ ដោយដឹងថាមានតែព្រះជាម្ចាស់ដែលជួយយើង អោយអ្វីៗទាំងអស់លូតលាស់យ៉ាងស្អាត។ អំបាញ់មិញនៅក្នុងសារលិខិតរបស់សម្ដេចប៉ាប យើងបានស្ដាប់ថា "នៅក្នុងឆ្នាំនៃជំនឿនេះ ខ្ញុំសុំអោយបងប្អូនសំឡឹងមើលទៅព្រះយេស៊ូ គឺព្រះអង្គពិតជាដើមកំណើតនៃជំនឿហើយធ្វើអោយជំនឿនេះបានពេញលក្ខណៈ ខ្ញុំក៏អញ្ជើញបងប្អូនអោយប្រកាសម្ដងទៀតថា ព្រះអង្គពិតជាដំណឹងល្អសម្រាប់មនុស្សលោកនាបច្ចុប្បន្នកាលនេះ"។ ស្ដាប់ប្រសាសន៍របស់សម្ដេចប៉ាប គឺណែនាំអោយយើងចូលយ៉ាងជ្រៅម្ដងទៀតនៅក្នុងជីវិតរបស់យើងជាគ្រីស្ដបរិស័ទ។ គ្រីស្ដបរិស័ទ មានន័យថាជារបស់ព្រះជាម្ចាស់តែម្ដង។ ដូចបងប្អូនដែលបានចូលការប្រគុំតន្ត្រីពីយប់មិញបានចាប់អារម្មណ៍ យើងមានសិល្បៈទាំងអស់ដែលជាស្នាដៃរបស់ព្រះសហគមន៍ទាំងមូល ដែលចង់បង្ហាញសមត្ថភាពអំពីសិល្បៈអំពីសេចក្ដីស្រលាញ់ដែលយើងមានចំពោះព្រះសហគមន៍ ប៉ុន្តែដោយសារយើងមានបាណើរនោះយើងបាននឹកឃើញ គឺអ្វីៗទាំងអស់ដែលយើងធ្វើគឺនៅក្រោមព្រះយេស៊ូដែលកំពុងមើលយើង។ ប៉ុន្តែយើងបានទុកបាណើរនៅទីនេះ ដោយនៅលើបាណើរនេះយើងមានព្រះភ័ក្ររបស់ព្រះយេស៊ូធំណាស់។ យើងសំឡឹងមើលព្រះយេស៊ូ ហើយព្រះយេស៊ូក៏សំឡឹងមើលយើងដែរ។ នេះណែនាំអោយជីវិតរបស់យើងទៅជាជីវិតដ៏អស្ចារ្យបំផុត ដោយសារយើងមានមូលដ្ឋានគ្រីស្ដតែមួយគត់គឺព្រះយេស៊ូ។ យើងឥតមានមូលដ្ឋានគ្រឹះពីរបី ដូចយើងបានស្ដាប់អំបាញ់មិញ យើងមានមូលដ្ឋានគ្រីស្ដតែមួយគត់គឺព្រះយេស៊ូដែលជាជីវិតរបស់យើង។ បីថ្ងៃកន្លងមកដែលយើងបានគិតខ្លះៗអំពីអាទថ៌កំបាំងនៃព្រះសហគមន៍ ណែនាំអោយព្រឹកនេះយើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់ព្រះសហ-គមន៍យើងខ្ញុំនៅក្នុងប្រទេសកម្ពុជា ដែលកំពុងលូតលាស់រីកចំរើនបន្តិចម្ដងៗ ពីមួយថ្ងៃទៅមួយថ្ងៃ។ ហេតុនេះហើយ គឺណែនាំឲ្យយើងអរព្រះគុណព្រះជាម្ចាស់។ បទពិសោធន៍ ដែលយើងមាននៅក្នុងបីថ្ងៃកន្លងមកណែនាំអោយយើងយល់ថាព្រះសហគមន៍ជាយើងទាំងអស់គ្នា។ ពេលយើងជួបគ្នារបៀបនេះណែនាំឲ្យយើងមានភាពកក់ក្ដៅ យើងមានអារម្មណ៍ថាយើងជាមហាគ្រួសារដ៏សុខសាន្តពិតមែន ដោយសារនេះជាព្រះសហគមន៍របស់យើង។ ណែនាំអោយយើងមានសេចក្ដីសុខ ណែនាំអោយយើងមានសេចក្ដីសង្ឃឹមថ្មី បន្តិចទៀតពេលយើងចេញបន្តធ្វើការបន្តរៀនសូត្របន្តរកស៊ី ដោយសារព្រះសហគមន៍របស់យើងណែនាំឲ្យយើងមានកំលាំងថ្មី។ យើងមានកំលាំងសារជាថ្មី ដោយសារបីថ្ងៃកន្លងមកដោយនាមព្រះយេស៊ូគ្រីស្ដយើងបានជួបជុំគ្នា ដើម្បីយល់ថាដើមជីវិតរបស់យើង និងចុងក្រោយបំផុតនៃជីវិតរបស់យើងគឺព្រះយេស៊ូតែម្ដង។ បទពិសោធនេះ ជាបទពិសោធន៍ដែលយើងមិនអាចភ្លេចបានទេ ហើយយូរៗម្ដងយើងត្រូវការមានឱកាសដូចនេះ ដើម្បីយល់ថាពិតមែនព្រះសហគមន៍យើងជាព្រះសហ-គមន៍ដ៏អស្ចារ្យ។ ពិតមែនព្រះសហគមន៍យើង ជាព្រះសហគមន៍របស់ព្រះយេស៊ូ ហើយខ្ញុំមិនមានកិត្តិយសណាស់ដោយសារ ខ្ញុំជាបុត្រធីតារបស់ព្រះជាម្ចាស់។ ហេតុនេះហើយអំបាញ់មិញដែលយើងបានស្ដាប់អំពីសិក្ខាសាលាទាំងប្រាំបី បងប្អូនបានចាប់អារម្មណ៍ហើយ។ ខ្ញុំសង្ឃឹមបន្តិចម្ដងៗ យើងយកលទ្ធផលនៃសិក្ខាសាលានេះ ដើម្បីបន្តរិះគិតអំពីរបៀបដែលយើងចង់កសាងព្រះសហគមន៍។ តើយើងចង់កសាងព្រះសហគមន៍របៀបណានៅលើទឹកដីប្រទេសកម្ពុជាគឺព្រះសហគមន៍របស់ព្រះយេស៊ូ។ អំបាញ់មិញយើងបានស្ដាប់ នៅក្នុងអត្ថបទទីពីរម្នាក់ៗត្រូវប្រយ័ត្ន

អំពីរបៀបដែលខ្លួនសង់ពីលើ គឺពីលើមូលដ្ឋានគ្រឹះតរបស់ព្រះយេស៊ូ។ ប៉ុន្តែយើងត្រូវការប្រុងប្រយ័ត្ន អំពីរបៀបដែលយើងសង់ក្នុងសិក្ខាសាលាដែលយើងមានទាំងប្រាំបីប្រធានបទ។ ប៉ុន្តែគ្រប់ការអប់រំ គ្រប់សិក្ខាសាលាដែលយើងមានជាប្រចាំ ជួយយើងដើម្បីគិតពិចារណា តើយើងចង់កសាងព្រះសហគមន៍ អោយយើងធ្វើប្រយ័ត្នអំពីរបៀប ដែលយើងកសាងព្រះសហគមន៍ពីលើ។ អត្ថបទដែលយើងបានស្តាប់ព្រឹកមិញ មានចំនុចខ្លះៗដែលជួយយើងអោយយើងគិតសារជាថ្មី អោយយើងប្រមូលចិត្តគំនិតរបស់យើងសារជាថ្មី របៀបថ្មីដើម្បីបន្តកសាងព្រះសហគមន៍របស់ព្រះយេស៊ូ។ ទីមួយ គឺព្រះជាម្ចាស់ មានតែព្រះជាម្ចាស់ដែលធ្វើអោយព្រះសហគមន៍ផុសឡើងបាន នេះអោយយើងទុកសម្រាប់ជីវិតរបស់យើង។ មិនត្រូវការសង្ឃឹមលើតែកម្លាំងរបស់យើង ជួនកាលយើងថាយើងអស់កម្លាំងណាស់ប៉ុន្តែបើយើងផ្ញើទៅលើព្រះជាម្ចាស់យើងទៅមុខបាន។ ពេលយ៉ូហាន២៣ បានបង្កើតមហាសន្និបាតវ៉ាទីកង់ទី២គាត់មិនដឹងទេថាគាត់ទៅណាគាត់គ្មានកម្លាំងតែគាត់បានផ្ញើ ទៅព្រះជាម្ចាស់ធ្វើអោយគាត់សម្រេចបាន។ដូចថ្ងៃនេះ យើងបានបើកទ្វារនៃព្រះសហគមន៍ព្រះសហគមន៍ដែលគ្មានជញ្ជាំងដែលមានខ្យល់ចេញចូល ប៉ុន្តែខ្យល់នេះជាព្រះវិញ្ញាណដ៏វិសុទ្ធដែលកំពុងណែនាំយើង។ ប្រសិនបើយើង សុខចិត្តផ្ញើជីវិតរបស់យើងទៅលើព្រះវិញ្ញាណដ៏វិសុទ្ធយើងអាចកសាងព្រះសហគមន៍របស់ព្រះជាម្ចាស់បាន។ បើយើងផ្ញើលើកម្លាំងរបស់យើង យើងទៅមិនរួចទេ យើងអាចសួរវ៉ាន់ណាសួរសុផលដែលបានសម្រុះសម្រួលកម្មវិធីនេះទាំងអស់នៅក្នុងបីថ្ងៃកន្លងមក។ ពីរថ្ងៃកន្លងមក យើងគិតថាទៅមិនរួចទេ តែយើងមានព្រះវិញ្ញាណដ៏វិសុទ្ធបានជំរុញយើង អោយយើងទៅមុខធ្វើអោយយើងបានជោគជ័យអស់ហើយ។ តែមិនមែនជោគជ័យដោយសារកម្លាំងរបស់យើង គឺជោគជ័យដោយសារយើងបានផ្ញើអ្វីៗទាំងអស់ ទៅលើព្រះយេស៊ូនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ។ ទីពីរព្រះយេស៊ូជាមូលដ្ឋានគ្រីស្ត ដែលខ្ញុំបាននិយាយហើយ។ ទីបី យើងទាំងអស់គ្នាយើងជាព្រះវិហារដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ នេះជាកិត្តិយសរបស់យើងជាតម្លៃថ្លៃថ្នូនៃជីវិតរបស់យើង។ ណែនាំអោយ យើងយល់ថាយើងទាំងអស់គ្នា យើងជាព្រះវិហាររបស់ព្រះជាម្ចាស់។ យើងទាំងអស់គ្នា យើងមានព្រះភ័ក្ររបស់ព្រះអង្គ ដែលសុខចិត្តធ្វើទីលំនៅក្នុងដួងចិត្តរបស់យើង។ ម្សិលមិញ នៅក្នុងសិក្ខាសាលាដែលខ្ញុំបានណែនាំ ខ្ញុំបានបំភ្លឺយើងជាព្រះសហគមន៍រួមគ្នា។ ប៉ុន្តែព្រះសហគមន៍ កើតដោយយើងម្នាក់ៗ។ ដើម្បីអោយយើងស្គាល់ការអស្ចារ្យនៃព្រះសហគមន៍ដោយសារ នៅជីនេះជាជីរបស់ព្រះសហគមន៍ថ្មីដែលនៅក្បែរនេះមានមន្ទីរទាំងអស់ដែលមាននៅក្នុងទីក្រុងភ្នំពេញដែលកំពុងសាងសង់ទាំងអស់នៅក្បែរទីនេះ។ ណែនាំអោយយើងបើកភ្នែកម្តងទៀត យើងមិនមែនព្រះសហគមន៍ សម្រាប់ព្រះសហគមន៍ យើងជាព្រះសហគមន៍របស់ព្រះយេស៊ូគឺសម្រាប់ពិភពលោកទាំងមូល។ អោយយើងបន្តបើកភ្នែកដើម្បីមើលបងប្អូនឯទៀតដែលជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដោយស្រលាញ់និងផ្តល់សេចក្តីសង្ឃឹម និងដោយយកចិត្ត ទុកដាក់។ ទីពីរព្រះយេស៊ូមានព្រះបន្ទូល សូមអញ្ជើញ ចុះមក ជាប្រញាប់មិនមែនចាំយូរឆ្នាំទៀតគឺឥលូវនេះ។ ព្រះយេស៊ូនៅ ពេលនោះអញ្ជើញលោកសាខេ មិនមែនលោកសាខេដែល អញ្ជើញព្រះយេស៊ូ។ ទីបីព្រះយេស៊ូចង់អញ្ជើញទៅណា? កុំអោយព្រះសហគមន៍ទៅជាកន្លែងមួយដែលយើងមិនហ៊ានចូល។បងប្អូនឃើញខាងមុខខ្ញុំមិនទាន់ដាក់ខ្លោងទ្វារ ដោយសារខ្ញុំខ្លាចពេលគេឃើញគេមិនហានចូល ដោយសារមានខ្លះគេថាជាកន្លែងឯកជនមិនហ៊ានចូលទេ។ ព្រះសហគមន៍ទៅជាក្រុមគ្រួសាររបស់យើងពិតមែន នេះជាអ្វីដែលសម្តេចប៉ាបបានរំលឹកអោយយុវជនយុវនារីទាំងអស់ យុវជន យុវនារី ជាទីស្រលាញ់ទាំងអស់សូមបងប្អូន កូនក្មួយអើយកុំភ្លេចព្រះសហគមន៍ជាគ្រួសារថ្មីរបស់បងប្អូន។ ដោយសារ លទ្ធផល ទីមួយ គឺលោកសាខេបានកែប្រែចិត្តគំនិត ហើយលោកសាខ មានជីវិតថ្មីលោកសាខេដែលជាអ្នកមាន លោកសាខេមិន ដែលនឹកដល់បងប្អូនឯទៀតៗ គាត់បានកែប្រែចិត្តគំនិតតែម្តង ភ្លាមជាប្រញាប់។ ព្រះជាម្ចាស់អញ្ជើញយើង ដែលជា ព្រះសហគមន៍ក្រីក្រ បំរើអ្នកក្រីក្រប៉ុន្តែយើងជាអ្នកមានដោយ សារយើងមានព្រះជាម្ចាស់ ដោយសារយើងបំរើ មនុស្ស ទាំងអស់ ដោយសារយើងដឹងថាយើងជាគ្រីស្តបរិស័ទមាន ន័យថាយើងជាសាវ័ករបស់ព្រះយេស៊ូ។

ជ័យយោព្រះសហគមន៍! ជ័យយោព្រះយេស៊ូ!។
អាម៉ែន។

# គណៈកម្មការពលកររៀបចំកម្មវិធីពលកររួមគ្នាដើម្បីសុខភាពនៅពេលអនាគត





គណៈកម្មការពលករភូមិភាគភ្នំពេញបានរៀបចំកម្មវិធីពលកររួមគ្នាដើម្បីអនាគត ហើយមានកម្មករ-កម្មការនីប្រមាណជា ២០០នាក់ បានចូលរួមក្នុងកម្មវិធីនេះកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១២ នៅសាលាបច្ចេកទេសដុនបូស្កូភ្នំពេញថ្មី។

លោក យ៉ាន ដឺហ្វុងជាអ្នកទទួលខុសត្រូវកម្មវិធីនេះមានប្រសាសន៍ថា កម្មវិធីនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីឲ្យកម្មករ-កម្មការនីទាំងនោះយល់ដឹងយ៉ាងច្បាស់ថា ជីវិតរបស់គេមានតម្លៃ។ លោកបន្តថា ដោយសារតែមានបញ្ហាប្រឈមមួយចំនួនដែលធ្វើឲ្យពួកគេមិនចាប់អារម្មណ៍ពីសុខភាពរបស់គេ។ លោកបានប្រាប់ឲ្យដឹងថា លក្ខខណ្ឌការងារ ការធ្វើការលើសម៉ោង បរិស្ថាននៅកន្លែងការងារ និងប្រាក់បៀវត្សបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាពរបស់គេ។ ចំពោះបញ្ហាសុខភាពរបស់កម្មករ លោកយ៉ានបានឲ្យដឹងថា ការិយាល័យពលករសហការជាមួយអង្គការពន្លឺមិត្តភាពដែលមានទីតាំងនៅទំនប់ទឹក ដើម្បីជួយកម្ម-ការនីដែលមានបញ្ហាទាក់ទងនឹងសុខភាព។

ក្នុងឱកាសនោះ លោកអភិបាលអូលីវីយេបានមានប្រសាសន៍ខ្លះដើម្បីលើកទឹកចិត្តឲ្យកម្មករទាំងអស់មានសេចក្ដីសង្ឃឹម និងយល់ថាជីវិតរបស់គេពិតជាមានតម្លៃ ដែលយើងម្នាក់ៗត្រូវតែយកចិត្តទុកដាក់។ កម្មវិធីនេះ ដែរក៏ជាឱកាសពិសេសមួយដើម្បីស្ដាប់សក្ខីភាពរបស់កម្មករផងដែរ។

## Young Workers' Festival: Health for the Future

The Labor Pastoral Committee organized a program called "Young Workers' Festival: Health for the Future" which was attended by about 200 young workers coming from different factories in the country. The festival was held on December 16, 2012 at Don Bosco Technical School.

Mr. Yann DEFOND, in charge of the committee, said that this event was held in order to give the workers a chance to promote their social, mental and emotional life and be more aware of their own dignity. "Health is a treasure that we need to care for; it's the most valuable gift in life," said Mr. Yann. He added that there are many challenges which could affect the worker's health, such as working conditions, overtime, working place and compensation. To help those workers who have problems with health, he cooperates with Clair Amitie Family Cambodia Center which provides care to some female workers.

Bishop Olivier gave an inspiring talk to encourage and to make those young workers feel that their lives are more important than anything else. "Everyone should be treated justly," the Bishop added.

# Activities of Bishop Olivier Schmitthaeusler, MEP
# Apostolic Vicar of Phnom Penh,
# January 2013

| | |
|---|---|
| ថ្ងៃទី០១ មករា | ៖ អភិបូជានៅផ្ទះលោកអភិបាលអេមីល ដេតម្ប |
| ថ្ងៃទី០២ មករា | ៖ ប្រជុំអំពីការរៀបចំ និងការសម្របសម្រួលកម្មវិធីសមាជ |
| ថ្ងៃទី០៥-០៧ មករា | ៖ សមាជអំពីមហាសន្និបាទវ៉ាទីកង់ទី២ និងអំពីព្រះសហគមន៍ |
| ថ្ងៃទី១០ មករា | ៖ ប្រជុំទីប្រឹក្សាផ្ទាល់លោកអភិបាល |
| ថ្ងៃទី១២ មករា | ៖ បង្រៀនទេវវិទ្យានៅសាលាអប់រំជំនឿគ្រីស្តបរិស័ទសន្តយ៉ូស្ទីន |
| ថ្ងៃទី០១៣ មករា | ៖ សិក្ខាសាលាសម្រាប់អ្នកចំណូលថ្មីនិងអភិបូជានៅព្រះវិហាសន្តយ៉ូសែប |
| ថ្ងៃទី១៤-១៨ មករា | ៖ បង្រៀននៅទេវវិទ្យាល័យអំពីលទ្ធិសាសនានៃព្រះសហគមន៍ |
| ថ្ងៃទី ២០ខែមករា | ៖ អភិបូជានៅព្រះសហគមន៍ចំប៉ា |
| ថ្ងៃទី ២១ខែមករា | ៖ សំណាក់ធម៌ជាមួយសម្ព័ន្ធកាតូលិកដើម្បីមេត្តាករុណានិងកាអភិវឌ្ឍន៍ |
| ថ្ងៃទី ២៤ខែមករា | ៖ ប្រជុំក្រុមប្រឹក្សាផ្ទាល់លោកអភិបាល។ ដំណើរទស្សនកិច្ច ប្រធានក្រុមបងស្រី Dominican |
| ថ្ងៃទី ២៥ខែមករា | ៖ សំណាក់ធម៌សម្រាប់ក្រុមបងស្រីមេត្តាករុណានិងប្រជុំក្រុម MEP |
| ថ្ងៃទី ២៦ខែមករា | ៖ បង្រៀនទេវវិទ្យានៅសាលាអប់រំជំនឿគ្រីស្តបរិស័ទសន្តយ៉ូស្ទីន |
| ថ្ងៃទី ២៧ខែមករា | ៖ ទស្សនកិច្ចតាកែវ |
| ថ្ងៃទី២៩១ខែមករា | ៖ សំណាក់ធម៌លោកបូជាចារ្យ |
| ថ្ងៃទី ៣០ខែមករា | ៖ ក្រុមប្រឹក្សាភូមិភាគ ៨:៣០-១៤:០០ នៅព្រះវិហាផ្សារតូច |
| ថ្ងៃទី ៣១ខែមករា | ៖ ប្រជុំក្រុមប្រឹក្សាលោកអភិបាល |

| | |
|---|---|
| 1 Jan | : Mass at Bishop Emile House |
| 2 Jan | : Meeting for coordination of the Congress |
| 5-7 Jan | : CONGRESS : Vatican II and the Church |
| 10 Jan | : Mission Council |
| 12 Jan | : TeachTheology at School of Faith : « St Justin » |
| 13 Jan | : Seminar for Neophyte and Mass at St Jospeh |
| 14-18 Jan | : Teach : Social Doctrine of the Church at Major Seminary |
| 20 Jan | : Mass at Champa |
| 21Jan | : Retreat with CatholicAllinace for Charityand Developpement |
| 24 Jan | : Mission Council am |
| | : Visit of the Superior of Dominican Sisters |
| 25 Jan | : Retreat for MC sisters |
| | : MEP meeting |
| 26 Jan | : TeachTheology at School of Faith : « St Justin » |
| 27 Jan | : VisitTakeo |
| 29 Jan | : Recollection for Priests |
| 30 Jan | : Diocesan Pastoral Council (8.30am -2pm at St Joseph) |
| 31 Jan | : Episcopal Council |

# រូបភាពប្រចាំខែ












**ព្រះសហាគមន៍ភូមិភាគភ្នំពេញ**

**ព្រឹត្តិបត្រ ជីវិត**

អ្នកទទួលខុសត្រូវៈ លោកអភិបាល  អូលីវិយេ ឆ្មិតអឺស្លែរ

Tel: 023 212 462

Email: apostolicvicariate.phnompenh@gmail.com

ការីនិពន្ធៈ ញឹប ញៀន

Email: markgnuen@gmail.com

ការិយាល័យផ្សព្វផ្សាយពត៌មានកាតូលិក

# ២៥ ផ្លូវ២៤២ បឹងព្រលឹត ៧មករា ភ្នំពេញ.

**Apostolic vicariate Phnom Penh**

**LIFE NEWSLETTER**

**Chairman:** Msgr. Olivier Schmitthaeusler.

**Tel:** 023 212 462

**Email:** apostolicvicariate.phnompenh@gmail.com

**Editor:** Gneb Gnuen

**Email:** markgnuen@gmail.com

**Catholic Social Communication**

#25, St 242, Boeung Prolit, 7 Makara, Phnom Penh.